# The Baptist Tabernacle of Los Angeles

1329 South Hope Street, L.A. Civic Center

Mailing Address:
P. O. Box 15308
Los Angeles, CA 90015
Phone: (213) 744-9999
E-mail: rlhymersjr@sbcglobal.net
www.sermonsfortheworld.com
www.baptisttabernacle.com




Dr. R. L. Hymers, Jr.
Senior Pastor

Dr. Christopher L. Cagan
Associate Pastor

Dr. Kreighton L. Chan
Assistant Pastor

ធ្នូ ២០១៦

ជូនចំពោះមិត្តជាទីស្រឡាញ់៖

នៅឆ្នាំនេះ  ព្រឹត្តិការណ៍ចម្បងនៅក្នុងក្រុមជំនុំយើងជាការរស់ឡើងវិញដែលព្រះបានចាត់បញ្ជូនមកយើ ងនៅក្នុងរបៀបតាមបែបបុរាណ។ គ្រួសារខ្ញុំ និងខ្ញុំបានទៅវិស្សមកាលនៅក្នុង    ទីក្រុងខែនខាន់ រដ្ឋមិសិចកូ។ ខ្ញុំបានចំនាយពេល១ថ្ងៃក្នុងចំនោមថ្ងៃផ្សេងទៀតនៅក្រោមថ្ងៃ និងនៅក្នុងបន្ទប់សណ្ឋាគារ ដើម្បីអានសៀវភៅមួយដែលប្រាប់អំពីការរស់ឡើងវិញនៅកោះឡេវីសនៅឆ្នេរខាងជើងនៃប្រទេសស្កត់ឡែន ដែលបានកើតឡើងនៅចន្លោះឆនាំ១៩៤៩ និង១៩៥៣។ ខណដែលខ្ញុំអានវា នោះព្រលឹងខ្ញុំផ្ទាល់ត្រូវបានរស់ឡើងវិញ។ ខ្ញុំបានចាប់ផ្តើមអធិស្ឋានជាខ្លាំង ដើម្បីឲ្យព្រះចាត់បញ្ជូនការរស់ឡើងវិញមកក្រុមជំនុំយើង។ នៅពេលយើងត្រលប់មកវិញ នោះខ្ញុំបានអធិប្បាយ៣ថ្ងៃ ហើយមានមនុស្សវ័យក្មេងជាច្រើនបានសង្រ្គោះ។ តែការរស់ឡើងវិញដ៏ធំបានកើតឡើងភ្លាមៗ ក្រោយពីរដូវក្តៅនោះវាជាថ្ងៃព្រហស្បត្តិ៍ល្ងាច ខែសីហា២៧។ ខ្ញុំបានសុំឲ្យមនុស្សវ័យក្មេងរបស់យើងទន្ទេញគម្ពីរអេសាយ ៦៤ :១-៣ « ឱបើសិនជាទ្រង់នឹងវែកផ្ទៃមេឃ ហើយយាងចុះមកទៅអេះ...»(អេសាយ ៦៤  :១-៤)។ ក្មេងៗ៣នាក់បានសូត្រខគម្ពីរទាំងនោះ។ ភ្លាមៗដែលមនុស្សវ័យក្មេងម្នាក់លោតកញ្ជោង ហើយស្រែកថា «ខ្ញុំបាត់បង់!» គេលុតជង្គង់ដោយជង្គក់ទាំងស្រែកយំ។ វាហាក់ដូចជានៅកន្លែងខុស ដោយសារតែគ្មានអារម្មណ៍សោះនៅយប់នោះ សូម្បីតែមិនមានការច្រៀងផង។ នៅក្នុងការប្រជុំពីរបីទាំងនោះនៅខែមករា និងខែសីហា ព្រះបានយាងចុះមក ហើយមានមនុស្សវ័យក្មេង២២នាក់បានសង្រ្គោះ ថែមទាងមានមនុស្ស១៤នាក់ថែមទៀតត្រូវបានរស់ឡើងវិញ ហើយពេញដោយព្រះវិញ្ញាណ។ ខ្ញុំបានឃើញការរស់ឡើងវិញដ៏ពេញដោយអំណាចចំនួន៣លើកនៅក្នុងទីក្រុងផ្សេងៗ មានអំណាចខ្លាំងមែនទែន មិនមែនជាការធម្មតា ហើយតាមខ្ញុំដឹង សព្វថ្ងៃនេះខ្ញុំមិនដែលឃើញសោះ។ តែការរស់ឡើងវិញនេះគឺជាការរស់ឡើងវិញមុនដំបូងបង្អស់ដែលព្រះបានចាត់បញ្ជូនមកក្រុមជំនុំយើងក្នុងរយៈពេល៤២ឆ្នាំ។ យើងបានអធិស្ឋានសុំការចាក់បង្ហូរព្រះវិញ្ញាណរបស់ព្រះសម្រាប់ឆ្នាំទាំងនោះ ហើយបន្ទាប់មកទ្រង់បានឆ្លើយតបសេចក្តីអធិស្ឋានយើង។ តែក្នុងពីរបីយប់នោះ យ៉ាងតិចណាស់មានមនុស្ស៣៦នាក់បានស្ថិតនៅក្រោមការប៉ះពាល់ចិត្ត ហើយ២២នាក់ក្នុងចំនោមនោះបានសង្រ្គោះ ថែមទាំងមាន១៤នាក់ផ្សេងទៀតត្រូវបានរស់ឡើងវិញ និងស្តារពីស្ថានភាពរាថយពីព្រះឡើងវិញ។ រឿងនេះបានកើតឡើងកាលខ្ញុំអធិប្បាយគម្ពីរអេសាយ ៦៤ :១-៣ម្តងហើយម្តងទៀត ហើយរាល់យប់មនុស្សបានច្រៀងបទពីផ្ទៃរឿងនៃការរស់ឡើងវិញម្តងហើយម្តងទៀត «សូមទ្រង់ចាក់បំពេញការជាក់ស្តែង ព្រះអង្គសង្គ្រោះអើយ ខ្ញុំអធិស្ឋាន សូមឲ្យខ្ញុំឃើញព្រះយេស៊ូវតែ១គត់នៅថ្ងៃនេះ ទោះបីជាឆ្លងកាត់ជ្រលងភ្នំក៏ដោយ ទ្រង់បាននាំផ្លូវខ្ញុំ សិរីល្អទ្រង់មិនព័ទ្ធជុំវិញខ្ញុំមិនដែលផុតទេ។ សូមទ្រង់ចាក់បំពេញការជាក់ស្តែង ព្រះអង្គសង្គ្រោះអើយ ទាល់តែមានសិរីល្អទ្រង់ ទើបវិញ្ញាណខ្ញុំនឹងភ្លឺឡើង។ សូមទ្រង់ចាក់បំពេញការជាក់ស្តែង ដើម្បីឲ្យមនុស្សទាំងអស់អាចឃើញរូបអង្គដ៏បរិសុទ្ធរបស់ទ្រង់ដែលបានឆ្លុះបញ្ចាំងនៅក្នុងខ្ញុំ»(«សូមទ្រង់ចាក់បំពេញការជាក់ស្តែង»ដោយលោកអេរីស ប៊ី គ្រីស្ទានសែន ១៨៩៥-១៩៨៥០។ រយៈពេលពីរបីដងនៅក្នុងការរស់ឡើងវិញ អារក្សបានមកដូចជាសត្វសឹង្ហដែលគ្រហឹម តែគ្រប់ពេលយើងអធិស្ឋាន វាបានថយចេញ ហើយព្រះវិញ្ញាណនៃព្រះបានយាងមក ទាំងទាញនាំមនុស្សទៅឯព្រះគ្រិស្ត។ សម្រាប់រយៈពេលពីរបីថ្ងៃនោះ យើងមានបទពិសោធន៍បីសាសនាគ្រិស្តដែលរស់នៅ ហើយអស់អ្នកណាដែលបាននៅទីនោះនឹងមិនដែលភ្លេចពីការនោះឡើយ ដរាបណាគេនៅរស់។ នៅក្នុងពេលនោះ បុរសវ័យក្មេង២នាក់បានថ្វាយខ្លួនបម្រើអធិប្បាយ។ ម្នាក់គឺជាកូនប្រុសអ្នកបកប្រែភាសាចិនរបស់យើងឈ្មោះ ណូអេ សោង។ ម្នាក់ទៀតគឺជាកូនប្រុសលោកបណ្ឌិតខាហ្គិនអាយុ២៣ឆ្នាំ ឈ្មោះ

យ៉ូហានសាំយ៉ូអេល ខាហ្គិនដែលទើបរៀនចប់នៅ ខាល ស្តេត អិល អេ ដោយទទួលបានបរិញ្ញាបត្រខាងផ្នែកភាពយុត្តិធម៌ក្នុងឧក្រិដ្ឋកម្ម។ គេទាំង២នាក់ជាគ្រូអធិប្បាយដ៏ឆ្នើម។ នៅពេលយ៉ូហានបានអធិស្ឋានមេរៀនមុនដំបូងរបស់គាត់ វាហាក់ដូចជាគាត់បានអធិប្បាយច្រើនជាង២០ឆ្នាំមកហើយ ហើយលោកណូអេសូម្បីអាចរើសបទចម្រៀងពីផ្ទៃរឿងមួយដែលស៊ីជាមួយការអធិប្បាយខ្លាំងៗ គាត់ច្រៀងចម្រៀង ហើយត្រលប់ទៅអធិប្បាយតាមរបៀបលោកបណ្ឌិត យ៉ូហាន សាំង និងលោកយ៉ូហាន អោ វ៉ាយស៍។ វាមិនអាចគួរឲ្យជឿ! អរគុណព្រះសម្រាប់បុរសវ័យក្មេងទាំងនេះ! ចាប់ពីខែមករា លោកយ៉ូហាននឹងរៀននៅសាកលវិទ្យាល័យប៊ីអូឡាថាល់ប៉ោតស្គូលខាងផ្នែកធ្វើជាគ្រូគង្វាល។ ទោះបីជាយ៉ាងណាក៏ដោយ គាត់ត្រឹមតែទើបបានអធិប្បាយ៣ ឬ៤ខែប៉ុណ្ណោះ គាត់ត្រូវបានគេអញ្ជើញទៅអធិប្បាយការប្រជុំបែបផ្សាយដំណឹងល្អនៅក្នុងប្រទេសឥណ្ឌាប៉ែកខាជើង ប្រទេសសារជាណរដ្ឋ និងឥណ្ឌាខាងត្បូង។ ខ្ញុំជឿថាគាត់នឹងអធិប្បាយពាសពេញ ពិភពលោកដូចជាគ្រូអធិប្បាយដ៏ល្បីម្នាក់នៅសតវត្សទី២១។ បើចង់អានចង់ការអធិប្បាយរបស់លោកយ៉ូហាន ឬលោកណូអេ សូមទៅកាន់គេហទំព័រ www.sermonsfortheworld.com ។ នៅពាក់កណ្តាលទំព័រខ្មៅ មានកន្លែងចុចមួយដែលប្រាប់ថា «សេចក្តីអធិប្បាយតាមភាសាអង់គ្លេស»។ សូមចុចទីនោះ នោះអ្នកនឹងឃើញទំព័រសម្រាប់ភាសារបស់អ្នក។ បើមានកន្លែងចុចលើទំព័រជាភាសារបស់អ្នក សូមចុចលើកន្លែងចុចសម្រាប់ការអធិប្បាយរបស់លោកបណ្ឌិត ហាយមើស៍ ឬមួយសម្រាប់លោក យ៉ូហានសាំយ៉ូអេល ខាហ្គិន ឬមួយសម្រាប់លោកណូអេ សោង ឬមួយសម្រាប់អ្នកអធិប្បាយផ្សេងទៀតដែលអធិប្បាយនៅក្នុងក្រុមជំនុំយើង។ បើគ្មានកន្លែងចុចលើទំព័រសម្រាប់ភាសាអ្នកទេ សូមទាញបញ្ជីចុះក្រោម នោះអ្នកនឹងឃើញសេចក្តីអធិប្បាយជាច្រើនដែលនឹងជាជំនួយ និងជាព្រះពរសម្រាប់អ្នក។

រឿងទី២ដ៏អស្ចារ្យបំផុតដែលបានកើតឡើងឆ្នាំនេះជាកំណើតរបស់ចៅស្រីមុនដំបូងរបស់យើងឈ្មោះ ហាណាខឹម ហាយមើស៍។ នាងបានកើតនៅខែមីនា ៣០ ចំពោះកូនប្រុសរបស់យើងឈ្មោះរ៉ាប៊ឺត ឡែសលី ហាយមើស៍ III និងប្រពន្ធជាទីស្រឡាញ់របស់គាត់ឈ្មោះ ជីន។ ហាណាគឺជាទារកដ៏ស្រស់ស្អាត ហើយអាចលើកខ្លួននាងបាន ថែមទាំងស្ទើរតែអាចដើរក្នុងទេះរួចហើយ។

ដូចខ្ញុំបានប្រសាសន៍ថា ប្រពន្ធខ្ញុំអ៊ីលីណា និងខ្ញុំបានយកម្តាយរបស់នាងឈ្មោះលីនដាទៅជាមួយជីន ឡែសលី និងវែស្លេ ដើម្បីទៅលេងនៅមាត់សមុទ្រក្នុងខែមករា។ យើងមានពេលដ៏គួរឲ្យចូលចិត្ត ទោះបីជាខ្ញុំមិនស្រួលខ្លួនដោយការប្រើថ្នាំពីការដែលខ្ញុំមានជំងឺមហារីកក៏ដោយ។ ម្យ៉ាងទៀត ជំងឺមហារីកហាក់ដូចជាស្ថិតនៅក្រោមការត្រួតត្រា ហើយប្រហែលជាបាត់ទៅហើយ។ ពេលវេលាត្រឹមតែប្រាប់ តែខ្ញុំបានស្រក២២គីឡូ ដែលជួយ។

ខ្ញុំលួចមើល «បញ្ជីពីប្រធានបទផ្សេងៗ»នៃរឿងរ៉ាវដែលបានកើតឡើងនៅឆ្នាំនេះ។ រ៉ូស ផែនណោល ខ្ទីនបានទទួលមរណៈភាពនៅខែកុម្ភៈ ១៣ នៅអាយុ៩៧។ ដាវីឌ រ៉ាលស្តូន រ៉ូឡែន វែសម៉ូសែន និងដែននី ថូម៉ាស់បានអធិប្បាយ ថែមទាំងបានផ្តល់តន្ត្រីនៅក្នុងរដូវរំលឹកខួបព្រះយេស៊ូវរស់ឡើងវិញ និងសម្រាប់ថ្ងៃខួបកំណើតអាយុ៧៥របស់ខ្ញុំ នៅខែមេសា ១២។ ខួបកំណើតអ្នកស្រីហាមើស៍តពីខែមេសា ១៦ និងឪពុករបស់នាង រ៉ាហ្វែអែល ខូអិឡា អាយុ៨៥ឆ្នាំដែលជិះយន្តហោះមក ហើយបានចំនាយពេលពីរបីថ្ងៃជាមួយយើង។

ក្រោយមករឿងដ៏ធំបន្ទាប់មកបានកើតឡើង។ ព្រះបានបង្ហាញខ្ញុំថា វាជាពេលដើម្បីផ្លាស់ប្តូរអ្វីសំខាន់ៗខ្លះនៅក្នុងក្រុមជំនុំរបស់យើង។ យើងបានបន្ថែមគ្រូជំនួយ៣នាក់ដែលជាបេក្ខជន លោកណូអេ សោង ដែក ហ្គែន និងអ៊ីរ៉ុនយ៉ែនស៊ី។ លោកយ៉ូហានខាហ្គិនបានអធិប្បាយមេរៀនមុនដំបូងរបស់គាត់នៅខែកក្កដា ១០ និងណូអេ សោងបានអធិប្បាយថ្ងៃទី១៧។ បុរសវ័យក្មេងទាំង២នាក់នោះជាគ្រូអធិប្បាយដ៏ឆ្នើម ដែលមិនគួរឲ្យជឿ! នៅខែកក្កដា ៣១ លោកជីម៉ូថេ ចាន់ និងឡារ៉ា អេស្កូប៉ាបានរៀនការ។ នៅខែសីហា ២១ ពេត្រុសស្ទេផាន ហ្គែនបានកើត។

ផ្នែកទី២នៃការរស់ឡើងវិញបានកើតឡើងនៅថ្ងៃព្រហស្បត្តិ៍ ខែសីហា ២៧។ យើងបានឃើញវានៅក្នុងការប្រជុំពិសេសៗទាំងនេះ នៅពេលយើងអធិស្ឋានដោយប្រុងប្រយ័ត្ន ហើយរក្សាទុកព្រះវិញ្ញាណនៃការអធិស្ឋានដែលព្រះបានបង្ហាញនៅក្នុងកម្មវិធីថ្វាយបង្គំព្រះទាំងនេះ តែនៅថ្ងៃដែលឆ្លាស់គ្នា នៅពេលយើងមិនផ្តោតសំខាន់លើការអធិស្ឋាន ព្រះគ្មានវត្តមានទាំងស្រុង ហើយគ្មានអ្វីកើតឡើង។ ដូច្នេះនេះជាបទពិសោធន៍ដែលយើងបានរៀន ទោះបីជាខ្ញុំបានឃើញការរស់ឡើងវិញធំៗ៣ដងដោយផ្ទាល់ដៃ មួយដែលបានកើតឡើងនៅក្នុងចំនួនមនុស្សប្រហែល៤នាក់ចំពោះក្រុមជំនុំចិន ដែលខ្ញុំបានចងចាំ។

លោកបណ្ឌិត ណៀល រីវើដ៏ជាប្រធាននៅសាកលវិទ្យាល័យឡូអ៊ីសាណាបាទីស្ទ បាននៅជាមួយយើងសម្រាប់សិក្ខាសិលាព្រះគម្ពីររបស់យើងនៅថ្ងៃពលកម្មចុងសប្ដាហ៍។ នៅខែវិច្ឆិការ ១៩ លោកវ៉េស្លេ ហាយមើស៍ គ្រីស្ទីន ហ្គូយេន អេដឺឡា មែនជីវ៉ា សែតសូកូសាប៉ាឡាហ្គា និងវើហ្គែល នីកខែលត្រូវបានធ្វើពិធីជ្រមុជទឹក។ នៅពេលតែ១ក្នុងការថ្វាយបង្គំព្រះ លោកយ៉ូហានសាំយ៉ូអែលខាហ្គិនត្រូវបានផ្ដល់សិទ្ធិប្រកាសដំណឹងល្អដោយក្រុមជំនុំរបស់យើង។ ថ្ងៃខាងមុខទៀតយើងមានការជប់លៀងថ្ងៃបុណ្យថ្លែងអំណរគុណជាមួយវ៉ាន់ ខ្លាកដោយវីឡូឡុង ហើយជីអោស្វ ម៉ែរីលលេងម្យ៉ាណូ។ ពេលវេលាអីក៏អស្ចារ្យម្ល៉េះដែលយើងមាន! ចុងបញ្ចប់ លោកដេវស្សោកនឹងត្រលប់ ទៅច្រៀងនៅជនបទ ហើយនិងច្រៀងតន្ត្រីពួកលោកខាលិចសម្រាប់យើងនៅឯការជប់លៀងថ្ងៃបុណ្យណូអែលខែធ្នូ ១៨។

ព្រះបើកទ្វារឲ្យយើងបន្ថែមភាសាទី៣៤របស់យើងគឺជា ភាសាណេប៉ាល់។ មនុស្សនៅក្នុងប្រទេសណេប៉ាល់អាចអានសេចក្ដីរបស់ខ្ញុំរៀងរាល់អាទិត្យ។ ប្រទេសណេប៉ាល់ជាកន្លែងដែលត្រូវការតម្រូវការ គេមានរញ្ជួយផែនដី២ដងកាលពីឆ្នាំមុន ហើយយើងសប្បាយចិត្តណាស់ដើម្បីអាចបន្ថែមភាសានៃប្រទេសដ៏តូចនេះតាមជួរភ្នំហាម៉ាល័យ ក្នុងបញ្ជីនៃសេចក្ដីអធិប្បាយដែលសរសេរដោយដៃរបស់យើង។ ស្ទើរតែគ្រប់សេចក្ដីអធិប្បាយដែលខ្ញុំអធិប្បាយឥឡូវនេះត្រូវបានបកប្រែទៅក្នុងភាសា៣ក្នុងទម្រង់សរសេរដោយដៃ។ គ្រប់សេចក្ដីអធិប្បាយទាំងអស់ត្រូវបានថតដោយកាំម៉ារ៉ាដែលជាឧបករណ៍មានគុណភាពល្អ ហើយផ្សាយពាសពេញពិភពលោកតាមយូថូប ហើយតាមគេហទំព័ររបស់យើងក្នុងភាសា៣ ភាសាចិន អេស្ប៉ាញ និងភាសាអង់គ្លេស។

ខ្ញុំមិនចូលចិត្តសារភាពវាទេ តែខ្ញុំចាស់ទៅហើយ។ ខ្ញុំមិនអាចលេងប៉ាលអោបច្រើនដូចខ្ញុំធ្លាប់នោះទេ ខ្ញុំមិនអាចទាល់តែសោះដូច្នេះខ្ញុំមិនបានបាត់បង់ច្រើនឡើយ! នោះជាអ្វីដែលខ្ញុំបាត់ភាគច្រើន!!! ប្រពន្ធខ្ញុំស្ទើរតែអញ្ជើញមនុស្សក្នុងក្រុមជំនុំទៅផ្ទះយើង ដែលយើងគ្មានកន្លែងដើម្បីសម្រាប់អាហារពេលល្ងាចនៅថ្ងៃថ្លែងអំណរគុណ។ យើងតែងតែមានពេលវេលាដ៏ល្អជានិច្ចជាមួយព្រឹត្តិការណ៍ទាំងនេះ។

វាជាទីសង្ឃឹមរបស់យើងដែលថា ព្រះគ្រិស្តនឹងត្រូវបានសម្ដែងឲ្យឃើញច្បាស់នៅក្នុងផ្ទះ និងក្នុងជីវិតរបស់អ្នកនៅរដូវថ្ងៃណូអែលដ៏ស្រស់ល្អនេះ។ សូមព្រះប្រទានពរអ្នកទាំងអស់!



លោកបណ្ឌិតហាយមើស៍និងអ៊ីលីណាជាមួយចៅស្រីឈ្មោះហាណា អាយុប្រហែល៤ម៉ោង។

ជូនចំពោះអ្នកក្នុងព្រះនាមព្រះយេស៊ូវ



R. L. Hymers, Jr.,
D.Min., Th.D., Litt.D.
ភីលីព ៤:១៣

*យូរៗម្ដងគ្រូអធិប្បាយទាំងអស់ជាប់គាំងសម្រាប់សេចក្ដីអធិប្បាយមួយ។ សូមផែកមើលសេចក្ដីអធិប្បាយខ្ញុំ នោះនឹងឃើញបើសិនជាអ្នកអាចទទួលជំនួយពីសេចក្ដីអធិប្បាយក្នុងចំនោមនោះ។ នោះជាមូលហេតុដែលសេចក្ដីអធិប្បាយទាំងអស់នៅទីនោះ។ ប្រហែលជាមានគ្រូអធិប្បាយ១២០,០០០ក្នុងប្រទេស២១៦ដែលអានសេចក្ដីអធិប្បាយរបស់ខ្ញុំ ហើយបានទទួលជំនួយពីសេចក្ដីអធិប្បាយទាំងនោះនៅឆ្នាំនេះ។ សូមទៅកាន់គេហទំព័រ* ***WWW.SERMONSFORTHEWORLD.COM*** *។*



លោកបណ្ឌិតហាយមើស៍ជាមួយលោកយ៉ូហានសាំយ៉ូអែលខាហ្គិន (ឆ្វេងដៃ) និងលោកណូអែ សោង(ស្តាំដៃ)។ ទាំង២នាក់បានថ្វាយខ្លួន ដើម្បីប្រកាសដំណឹងល្អ ហើយនឹងរៀនដើម្បីធ្វើជាគ្រូគង្វាល។





លោកបណ្ឌិតហាយមើស៍ជាមួយលោកយ៉ូហានខាហ្គិន កាលគាត់ត្រូវបានផ្តល់សិទ្ធិចំពោះព័ន្ធកិច្ចដំណឹងល្អ។



អេជីឡាមែនជីវ៉ាត្រូវបានទទួលពិធីជ្រមុជទឹកនៅអាយុ៨៧ដោយលោកបណ្ឌិតហាយមើស៍។



លោកបណ្ឌិតហាយមើស៍ធ្វើពិធីជ្រមុជទឹកលោក វើហ្គែល និចខែល។



ខួបអាពាហ៍ពិពាហ៍៣៤ឆ្នាំរបស់លោកបណ្ឌិតហាយមើស៍ និងអ្នកស្រីហាយមើស៍



វ៉េហ្វៃអែល ខ្សូអិលទ្យ៉ា(អ៊ឹល) ឡែសល្លី ហាយមើស៍ ជីនហាយមើស៍លោកបណ្ឌិតហាយមើស៍និងអ្នកស្រីហាយមើស៍ជាមួយទារកហាណា លោកជោននី ខឹម និងអ្នកស្រីខឹម។

*សូមមើលកាន់គេហទំព័រក្រុមជំនុំរបស់យើងតាម* ***WWW.BAPTISTTABERNACLE.COM.***
*គេហទំព័រនៃសេចក្តីអធិប្បាយរបស់យើងផ្តល់ជូននូវការសរសេរដោយពីមួយពាក្យមួយពាក្យចំនួនរាប់រយ នៅក្នុងភាសា៣៤តាម* ***WWW.SERMONSFORTHEWORLD.COM.***



លោក យ៉ាកុប រ៉ូផ និងអ្នកស្រីរ៉ូប។ នាងជាអ្នករៀបចំក្រុមជំនុំ



លោកបណ្ឌិយហាយមើស៍ជាមួយអ្នកស្រីរ៉ូស ផៃនណោ ខ្វីន



វេវ ម៉ាកុសប៉ាកខ្លីជាមួយលោកបណ្ឌិតហាយមើស៍
និងអ្នកស្រីហាយមើស៍នៅថ្ងៃចូលឆ្នាំសកល។



លោកបណ្ឌិតចាន់រៀបចំមង្គលការកូនប្រុសគាត់ឈ្មោះធីម៉ូថេ
និងឡារ៉ា អេស្តូប៉ា។



លោកបណ្ឌិតហាយមើស៍ និងអ្នកស្រីហាយមើស៍ជាមួយម្តាយអ្នក
ស្រីហាយមើស៍ឈ្មោះលីនដា ឡៃស្លី និងវៃស្លី និងជីន ហាយមើស៍។



( ពីខាងឆ្វេង )លោកបណ្ឌិតហាយមើស៍ជាមួយទារកហាណា
អ្នកស្រីហាយមើស៍ ឡៃស្លី និងជីនហាយមើស៍។

*សូមមើលកាន់គេហទំព័រក្រុមជំនុំរបស់យើងតាម* ***WWW.BAPTISTTABERNACLE.COM.***
*គេហទំព័រនៃសេចក្តីអធិប្បាយរបស់យើងផ្តល់ជូននូវការសរសេរដោយពីមួយពាក្យមួយពាក្យ*
*ចំនួនរាប់រយ នៅក្នុងភាសា៣៤តាម* ***WWW.SERMONSFORTHEWORLD.COM.***